00637335

E5/1

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 01 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២-១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សម្ងាត់ / Confidential / Confidentiel

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ: សាធារណៈ / Public

ឈ្មោះមន្ត្រីដែលបានពិនិត្យ: [handwritten name] ៣១-មករា-២០១១

ហត្ថលេខា: [signature]

---

**សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងបណ្ដឹងរបស់ អៀង សារី សុំប្ដឹងជំទាស់ចៅក្រម និល ណុន**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| **សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:** | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| ពេជ អង្គ | ចៅក្រម ធូ មណី | |
| Elisabeth SIMONNEAU FORT | | **មេធាវីការពារក្ដី:** |
| | | សុន អរុណ |
| | | Michiel PESTMAN |

00637336

ES|L

០០២-១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

Victor KOPPE

អាង ឧត្តម

Michael G. KARVANVAS

ផាត់ ពៅស៊ាង

Diana ELLIS

ស សូវាន

Jacques VERGES

Phillipe GRECIANO

E5/1

០០២-១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

# សំណើ

១. អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក សហព្រះរាជអាជ្ញាស្នើសុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងបណ្តឹងរបស់ អៀង សារី សុំប្តឹងជំទាស់ចៅក្រម និល ណុន (បណ្តឹង) អនុលោមតាមវិធាន ៣៤(២)។ ភាគីបានទទួលការជូនដំណឹងអំពីបណ្តឹងនេះនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១[1]។ បណ្តឹងនោះលើកឡើងនូវបញ្ហាអង្គហេតុ និងអង្គច្បាប់ស្មុគស្មាញនានាដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការជំនុំជម្រះលើករណី អៀង សារី និងជនជាប់ចោទ ៣ នាក់ទៀត។ សហព្រះរាជអាជ្ញាជឿជាក់ថា ចម្លើយតបរបស់ខ្លួនអាចជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចលើបណ្តឹងនេះ។

២. គេនៅពុំទាន់ដឹងថា ពេលណាអង្គជំនុំជម្រះសាលាដំបូងនឹងចាត់ការលើបណ្តឹងនេះនៅឡើយទេ ដោយហេតុថាវិធានផ្ទៃក្នុងមានចែងបញ្ញត្តិផ្ទុយគ្នា ពាក់ព័ន្ធនឹងពេលវេលាដែលចៅក្រមដែលរងការប្តឹងនោះមានសិទ្ធិដាក់សារណាជាលាយលក្ខណ៍អក្សរ ឆ្លើយតបទៅនឹងបណ្តឹងជំទាស់នោះ។ ទោះបីវិធាន ៣៤(៧) ផ្តល់សិទ្ធិឱ្យចៅក្រមនោះដាក់សារណាឆ្លើយតបក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីបណ្តឹងនេះក្តី ក៏យើងនៅពុំទាន់ដឹងនៅឡើយថារយៈពេល១០ថ្ងៃនោះ គិតចាប់ពីថ្ងៃដាក់បណ្តឹងនោះ អនុលោមតាមវិធាន ៣៤(៣) ឬគិតចាប់ពីពេលដែលតុលាការប្រកាសទទួលស្គាល់បណ្តឹងនោះ នៅពេលសវនាការបឋម អនុលោមតាមវិធាន៣៤(៤)(គ) នៅឡើយទេ។

៣. ពិសេសជាងនេះ មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (វិសោធនកម្មលើកទី៥) (សេចក្តីណែនាំអនុវត្តន៍) ទុករយៈពេល៥ថ្ងៃ សម្រាប់ឱ្យភាគីឆ្លើយ

---

[1] បណ្តឹងរបស់លោក អៀង សារី សុំប្តឹងជំទាស់ចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថាគាត់បានទទួលយកសំណូក និងសំណើសុំឱ្យមានសវនាការជាសាធារណៈ ឬជម្រើសផ្សេងពីនេះអនុញ្ញាតឱ្យដាក់ចម្លើយតបទៅនឹងអំណះអំណាងនានាដាក់ដោយចៅក្រម និល ណុន ជាកិច្ចឆ្លើយតបទៅនឹងពាក្យបណ្តឹងនេះ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ឯកសារ E5។

តបទៅនឹងពាក្យសុំ និងរយៈពេល១៥ថ្ងៃ សម្រាប់ឆ្លើយតបទៅនឹងសារណា។ យើងសូមអះអាងថាការឆ្លើយតបទៅនឹងបណ្ដឹងឧិតចិត្តនេះក្នុងរយៈពេល៥ថ្ងៃ គឺពុំគ្រប់គ្រាន់ឡើយ ដោយយោងទៅលើភាពស្មុគស្មាញនៃបញ្ហា ការស្រាវជ្រាវ ការបកប្រែ និងពិសេសពេលរយៈពេល៥ថ្ងៃនេះក៏រួមមានទាំងថ្ងៃចុងសប្ដាហ៍ផងដែរ។

៤. ដោយយោងទៅលើភាពស្រពេចស្រពិលផ្នែកនីតិវិធីនេះ និងរយៈពេលដ៏ខ្លីក្នុងការឆ្លើយតបទៅនឹងបញ្ហាសំខាន់ៗ ដូចមានចែងក្នុងសេចក្ដីណែនាំអនុវត្តន៍ សហព្រះរាជអាជ្ញាស្នើសុំពន្យារពេលក្នុងការដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងនេះ បើយល់ឃើញថាចាំបាច់ ។ ការពន្យារនេះមានរយៈពេលចំនួន ១៥ ថ្ងៃ បន្ទាប់ពីចៅក្រមដែលរងការប្ដឹងនោះបានដាក់សារណាជាលាយលក្ខណ៍អក្សររបស់គាត់ ឬប្រសិនបើគាត់ពុំបានដាក់សារណាជាលាយលក្ខណ៍អក្សរទេ សហព្រះរាជអាជ្ញានឹងដាក់ចម្លើយតបរបស់ខ្លួនក្នុងរយៈពេល១៥ថ្ងៃ ក្រោយថ្ងៃទទួលដំណឹងថាពុំមានការដាក់សារណាទេ។ សហព្រះរាជអាជ្ញាសូមឯកភាពជាមួយមេធាវីការពារក្ដី ដែលថាបណ្ដឹងនេះគួរត្រូវបានចាត់ការឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមតាមការស្នើសុំរបស់ អៀង សារី ដើម្បីគាំទ្របណ្ដឹងរបស់ខ្លួន[2] សហព្រះរាជអាជ្ញានឹងធ្វើការឆ្លើយតបក្នុងរយៈពេល ១៥ ថ្ងៃនៃប្រតិទិន គិតចាប់ពីពេលជូនដំណឹង ដូចមានចែងក្នុងសេចក្ដីណែនាំអនុវត្តន៍។

[2] សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងបណ្ដឹងរបស់លោក អៀង សារី សុំប្ដឹងឧិតចិត្តចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថាគាត់បានទទួលយកសំណូក ដោយស្នើសុំ ឬចេញដីកាបង្គាប់ឱ្យអ្នកផលិតភាពយន្ត AMANDA PIKE ឱ្យលាតត្រដាងបង្ហាញខ្សែភាពយន្តនៃកិច្ចសម្ភាសន៍របស់គាត់ជាមួយចៅក្រម និល ណុន និង លិខិតអនុញ្ញាតឱ្យចាក់ផ្សាយដែលមានហត្ថលេខារបស់លោក និល ណុន ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១, ឯកសារ E6។

00637339

E5/1

០០២-១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

សូមលោកចៅក្រមទទួលនូវក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ២៤ មករា ២០១១ | ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |



សំណើរបស់ ក.ស.ព ស្នើសុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងបណ្តឹងជំទាស់របស់ អៀង សារី អនុលោមតាមវិធាន៣៤(២)